គណបក្ស សិទ្ធិមនុស្ស

HUMAN RIGHTS PARTY

បំរើ ការពារ កសាង

កើតពីប្រជាពលរដ្ឋ របស់ប្រជាពលរដ្ឋ ដើម្បីប្រជាពលរដ្ឋ

ព្រឹត្តិប័ត្រព័ត៌មានប្រចាំសប្តាហ៍ ថ្ងៃសុក្រ ទី២៧ ខែកុម្ភៈ ឆ្នាំ២០០៩ ព្រឹត្តិប័ត្រលេខ០៧៤ ឆ្នាំទី២



| មាតិកាព័ត៌មាន | ទំព័រ |
| --- | --- |
| -ថ្នាក់ដឹកនាំគណបក្សសិទ្ធិមនុស្ស ចុះជួបសកម្មជននៅខេត្តព្រៃវែង | ១ |
| -ប្រជាពលរដ្ឋកំពុងព្រួយបារម្ភពីការ ចូមដីពីធន្លេយ៉ាងអនាធិបតេយ្យ | ២ |
| -ថ្នាក់ដឹកនាំគណបក្សសិទ្ធិមនុស្ស ចុះជួបសកម្មជននៅស្រុកបរសេដ្ឋ ខេត្តកំពង់ស្ពឺ | ២ |
| -ក្រុមអាជីវករផ្សារអូរឡាំពិកត្រូវ អាជ្ញាធរចុះរុះរើតូបតាំងពីព្រលឹម | ៣ |
| -អាជ្ញាធរស្រុកកំពង់លែងរងការចោទ ប្រកាន់ថាលួចលក់បឹងធម្មជាតិ | ៣ |


## ថ្នាក់ដឹកនាំគណបក្សសិទ្ធិមនុស្ស ចុះជួបសកម្មជននៅខេត្តព្រៃវែង

កាលពីព្រឹកថ្ងៃទី២១ ខែកុម្ភៈ លោក **កឹម សុខា** ប្រធានគណបក្សសិទ្ធិមនុស្សបានមានប្រសាសន៍ប្រាប់សកម្មជន និងអ្នកគាំទ្រគណបក្សសិទ្ធិមនុស្សនៅឃុំជ័យកំពត ស្រុកព្រះស្តេច ខេត្តព្រៃវែងថា នៅស្រុកខ្មែរខ្វះលក្ខណ:សម្បត្តិប្រជាធិបតេយ្យច្រើនណាស់ ហើយបញ្ហាធំរបស់ប្រជាពលរដ្ឋនៅតាមមូលដ្ឋាន គឺពួកគាត់ចង់បោះឆ្នោតជ្រើសរើសមេភូមិដោយផ្ទាល់ ។ ប្រជាពលរដ្ឋមិនចង់ទុក ឬតែងតាំងមេភូមិដោយបោះឆ្នោតអសកល ដែលនៅតែដដែលនោះទេ ។ ប្រជាពលរដ្ឋប្រមាណ៨៥%បានលើកឡើងថា ជីវភាពរស់នៅរបស់ពួកគាត់ គឺពាក់ព័ន្ធនឹងប្រធានភូមិ ដូច្នេះពួកគាត់ចង់បោះឆ្នោតជ្រើសរើសមេភូមិដោយផ្ទាល់ ។ លោក **កឹម សុខា** បញ្ជាក់យ៉ាងច្បាស់ៗថា ប្រការដែលគណបក្សកាន់អំណាចយកមេភូមិមកគាបសង្កត់ តាមដានប្រជាពលរដ្ឋ ដែលទង្វើបែបនេះត្រូវលោកចាត់ទុកថា ជារបបផ្តាច់ការ ហើយមេភូមិមិនគួរណាតំណាងឱ្យបក្សនោះទេ ។ លោកបន្តទៀតថា ប្រជាធិបតេយ្យនៅក្នុងស្រុកយើងកំពុងតែដើរតាមផ្លូវកុំម្មុយនីស្តនៅឡើយទេ លោកថាប្រទេសយើងមានគណបក្សច្រើនមែន ប៉ុន្តែនៅតែផ្តាច់ការ និងកាន់កាប់អំណាចទាំងបីដោយគណបក្សតែមួយ ។

សកម្មជនជាន់ខ្ពស់គណបក្សសិទ្ធិមនុស្ស នៅខេត្តព្រៃវែងថ្លែងថា ការប្រជុំសំណេះសំណាលដែលរៀបចំធ្វើនៅឃុំជ័យកំពតមានការចូលរួមពីសកម្មជន និងអ្នកគាំទ្រនៅក្នុងឃុំយ៉ាងច្រើន និងជាពិសេសមានការចូលរួមពីសកម្មជនគណបក្សសមរង្ស៊ីទៀតផង ។ លោកបានបន្តទៀតថា សកម្មជនគណបក្សសិទ្ធិមនុស្សនៅក្នុងស្រុកព្រះស្តេចនៅតែស្មោះស្ម័គ្រ និងដើរតាមមាគ៌ាគណបក្សយ៉ាងពេញទំហឹង ។ រីឯសម្ព័ន្ធភាពរវាងគណបក្សសិទ្ធិមនុស្ស និងគណបក្សសមរង្ស៊ី ប្រជាពលរដ្ឋនៅតាមមូលដ្ឋានដែលគាំទ្រគណបក្សមានប្រជាធិបតេយ្យ ដូចជាគណបក្សសិទ្ធិមនុស្ស និងគណបក្សសមរង្ស៊ីជាដើម បើទោះបីជាជីវភាពរស់នៅរបស់ប្រជាពលរដ្ឋនៅ តាមមូលដ្ឋានមានភាពខ្វះខាតច្រើន ។

## ប្រជាពលរដ្ឋកំពុងព្រួយបារម្ភពីការបូមដីពីទន្លេយ៉ាងអនាធិបតេយ្យ

ប្រជាពលរដ្ឋនៅភូមិកោះតេជោ ឃុំគគីរធំ ស្រុកគៀនស្វាយ ខេត្តកណ្តាល រាប់ពាន់គ្រួសារកំពុងព្រួយបារម្ភអំពីក្រុមហ៊ុនយួន បូមដីខ្សាច់នៅក្នុងទន្លេមេគង្គ បណ្តាឱ្យបាក់ដី ដែលធ្វើឱ្យប៉ះពាល់ដល់លំនៅឋានរបស់ប្រជាពលរដ្ឋ ។ អ្នកភូមិម្នាក់ក្នុងចំណោមរាប់ពាន់គ្រួសារបាននិយាយថា មានក្រុមហ៊ុនយួនបាននឹងកំពុងតែធ្វើអាជីវកម្មបូមដីពីទន្លេមេគង្គរាល់ថ្ងៃ ក្នុងកិច្ចសន្យារយៈពេល៩៥ឆ្នាំឯណោះ ហើយពេលនេះអ្នកភូមិកំពុងព្រួយបារម្ភខ្លាចក្រែង ការបូមដីនេះធ្វើឱ្យបាក់ច្រាំងទន្លេនារដូវវស្សាខាងមុខនេះ ។ ក្រុមហ៊ុនយួនដែលធ្វើអាជីវកម្មបូមខ្សាច់នៅម្តុំបឹងក្អែក ក្នុងដែនដីខេត្តព្រៃវែង ហើយឥឡូវនេះក្រុមហ៊ុននោះបានបូមខ្សាច់នៅក្នុងភូមិសាស្ត្រ ភូមិកោះតេជោ ខេត្តកណ្តាល ។ លោកបន្តទៀតថា ក្រុមហ៊ុនយួននេះបូមខ្សាច់២-៣ឆ្នាំកន្លងមកហើយ ប៉ុន្តែកាលពីមុននេះបូមខ្សាច់ក្នុងរូបភាពតូចតាច ឥឡូវនេះសកម្មភាពបូមខ្សាច់ជាទ្រង់ទ្រាយធំ ដោយក្រុមហ៊ុនប្រើសាឡង់ប្រមាណ២០គ្រឿង ចាប់ផ្តើមបូមខ្សាច់តាំងពីម៉ោង៩ព្រឹក រហូតដល់ម៉ោង៦ល្ងាចទើបឈប់ ។ ជាមួយគ្នានេះដែរអ្នកភូមិបានផ្តិតមេដៃប្តឹងក្រុមហ៊ុននេះទៅអាជ្ញាធរ ប៉ុន្តែមិនមានដំណោះស្រាយទាល់តែសោះ ។

ទាក់ទិននឹងក្តីបារម្ភរបស់ប្រជាពលរដ្ឋ នៅភូមិកោះតេជោ លោក **ហេង ធាម** អភិបាលស្រុកគៀនស្វាយបានបញ្ជាក់ថា ទីតាំងបូមខ្សាច់របស់ក្រុមហ៊ុននោះ ស្ថិតនៅទីតាំងភូមិសាស្ត្រខេត្តព្រៃវែង ហើយអាជ្ញាប័ណ្ណធ្វើអាជីវកម្មស្ថិតនៅខេត្តព្រៃវែង និងមានការអនុញ្ញាតពីក្រសួងធនធានទឹក ហើយក៏ហួសដែនសមត្ថកិច្ចរបស់លោកផងដែរ ។ លោកបន្តទៀតថា ក្រុមហ៊ុនដែលធ្វើអាជីវកម្មបូមខ្សាច់នៅក្នុងស្រុកកៀនស្វាយ មានប្រហែល១-២ប៉ុណ្ណោះដែលធ្វើអាជីវកម្មនៅទន្លេបាសាក់ និងទន្លេមេគង្គដែលមានអាជ្ញាប័ណ្ណរបស់ក្រសួងត្រឹមត្រូវ ។

លោក **អ៊ូ ច័ន្ទឫទ្ធិ** សមាជិករដ្ឋសភាគណបក្សសិទ្ធិមនុស្ស និងជាអ្នកតំណាងរាស្ត្រខេត្តកណ្តាលផងនោះ បានបញ្ជាក់ថា លោកក៏ចុះទៅដល់មូលដ្ឋានជួបប្រជាពលរដ្ឋជាច្រើននៅទីតាំងបូមដីនោះ ហើយប្រជាពលរដ្ឋក៏បានសំដែងការព្រួយបារម្ភ ដោយសារការបូមខ្សាច់ពីបាតទន្លេនេះដែរ ។ លោកបន្ថែមថា ប្រសិនបើក្រុមហ៊ុននៅតែបន្តការបូមខ្សាច់បន្តទៀត នឹងធ្វើឱ្យបាក់ច្រាំងទន្លេជាក់ជាមិនខាន ដូច្នេះបើទោះបីជាក្រុមហ៊ុននោះមានអាជ្ញាបណ្ណក៏ដោយក៏អាជ្ញាធរពិនិត្យ ស៊ើបអង្កេតឡើងដើម្បីចាត់វិធានការការពារកុំឱ្យប៉ះពាល់ដល់ប្រជាពលរដ្ឋ ។

## ថ្នាក់ដឹកនាំគណបក្សសិទ្ធិមនុស្សចុះជួបសកម្មជននៅស្រុកបរសេដ្ឋ ខេត្តកំពង់ស្ពឺ

លោក **ប៉ែន សុវណ្ណ** ប្រធានគណៈកម្មាធិការវិន័យរបស់គណបក្សសិទ្ធិមនុស្សបានមានប្រសាសន៍ទៅកាន់ប្រជាពលរដ្ឋ និងសកម្មជនគណបក្សសិទ្ធិមនុស្សនៅភូមិត្រពាំងផ្លុង ឃុំគិរីមានជ័យ ស្រុកបរសេដ្ឋ ខេត្តកំពង់ស្ពឺ កាលពីព្រឹកថ្ងៃទី២៤ ខែកុម្ភៈនេះថា អ្នកមានអំណាច មានលុយគេរំលោភយកដីប្រជាពលរដ្ឋទាំងកំរោលពីព្រោះអាជ្ញាធរមូលដ្ឋានបានយកលុយពីពួកឈ្មួញទាំងនោះ ដែលធ្វើឱ្យប្រជាពលរដ្ឋជាច្រើនយំស្រែក ដោយសារការបាត់បង់ដីធ្លី ដីលំនៅឋានរបស់ពួកគាត់ ។ លោកបានបន្តទៀតថា នៅក្នុងស្រុកបរសេដ្ឋមានបឹងបួរប្រមាណ១៣០០បឹង ត្រូវបានអាជ្ញាធរមូលដ្ឋានលក់ទៅឱ្យឈ្មួញដោយសារ តែមុនពេលបោះឆ្នោតអាជ្ញាធរទាំងនោះបានចំណាយលុយយ៉ាងច្រើនទៅឱ្យប្រជាពលរដ្ឋ ដើម្បីទទួលចំណេញសន្លឹកឆ្នោត ។

នៅថ្ងៃនោះដែរ លោក **គឹម សុខា** ជាប្រធានគណបក្សសិទ្ធិមនុស្សមានប្រសាសន៍ថា ផ្លូវ ស្ពានដែលកើតមានសព្វថ្ងៃនេះពុំមែនជាលុយរបស់បុគ្គលណាម្នាក់ទេ ពោលគឺជាលុយជំនួយពីសហគមន៍អន្តរជាតិសំរាប់កសាងផ្លូវ ស្ពាន សាលារៀនពីព្រោះខ្មែរយើងបានចុះសន្ធិសញ្ញានៅទីក្រុងប៉ារីសថ្ងៃទី២៣ ខែតុលា ឆ្នាំ១៩៩១ ហើយចាប់តាំងពីមានសន្ធិសញ្ញានោះមក សហគមន៍អន្តរជាតិតែងតែផ្តល់ជំនួយឱ្យខ្មែរយើង ។ បច្ចុប្បន្នអំពើពុករលួយ គឺកើតមានតាំងពីថ្នាក់ក្រោមរហូតដល់ថ្នាក់លើ ហើយក៏មិនមានវិធានការណាបង្ក្រាបនោះទេ គឺមានតែថាកំចាត់ៗតែប៉ុណ្ណោះ ។ តែបញ្ហាធំរបស់

ប្រជាពលរដ្ឋខ្មែរយើង៨០% ជាកសិករអត់មានដីធ្វើស្រែចំការគ្រប់គ្រាន់សំរាប់ចិញ្ចឹមជីវិត ហើយទំនិញនៅតែឡើងថ្លៃជាបន្តបន្ទាប់ ។

បច្ចុប្បន្នប្រជាពលរដ្ឋដែលធ្លាប់តែពឹងអាស្រ័យបឹងបួរទាំងនោះដើម្បីប្រកបរបរកសិកម្ម និងនេសាទលក្ខណៈគ្រួសារកំពុងជួបប្រទះនឹងផលវិបាក ។

## ក្រុមអាជីវករផ្សារអូរឡាំពិកត្អូញ អាជ្ញាធរចុះរុះរើតូបតាំងពីព្រលឹម

ក្រុមអាជីវករផ្សារអូរឡាំពិក៣០នាក់ ក្នុងចំណោមអាជីវករប្រមាណ៥០០នាក់ បានមកតវ៉ានៅមុខសាលារាជធានីភ្នំពេញកាលពីព្រឹកថ្ងៃទី២៦ ខែកុម្ភៈនេះ ដើម្បីឱ្យអាជ្ញាធររាជធានីភ្នំពេញជួយដោះស្រាយបញ្ហាការលក់ដូររបស់ពួកគាត់ ដែលត្រូវបានអាជ្ញាធរបណ្តេញរុះរើទាំងបង្ខំនៅម៉ោង២ទៀបភ្លឺ ថ្ងៃទី២២ ខែកុម្ភៈ ។

ស្ត្រីអាជីវករផ្សារអូរឡាំពិកដែលបានមកតវ៉ានៅព្រឹកនេះដែរបានថ្លែងទាំងទឹកភ្នែកថា អាជីវករជិត៥០០នាក់ដែលអាជ្ញាធរបណ្តេញចេញ ឱ្យទៅលក់ដូរនៅម្តុំអាងទឹកល្វទឹកស្អុយ ក្នុងសង្កាត់ទួលស្វាយព្រៃ ខណ្ឌចំការមននោះពួកគាត់បដិសេធថា មិនលក់ដូរនៅទីនោះទេ ពីព្រោះទីតាំងនៅទីនោះមានទឹកស្អុយខ្លាំងណាស់ ដែរមិនអាចធ្វើឱ្យពួកគាត់លក់ដូរបាន ហើយថែមទាំងប៉ះពាល់ដល់សុខភាពទៀតផង ។ ដូច្នេះហើយទើបពួកគាត់មិននាំគ្នាទៅលក់ដូរនៅទីតាំងថ្មី ទៅតាមការកំណត់របស់សាលារាជធានីភ្នំពេញនោះទេ ដោយសម្រេចបន្តការលក់ដូរនៅតាមសំយាបផ្ទះរបស់គេស្ថិតនៅផ្លូវលេខ៣១០ កែងផ្លូវ១៩៣ ។ ស្ត្រីរូបនោះថ្លែងទៀតថាឥឡូវនេះ អាជ្ញាធរបានចេញបទបញ្ជាឱ្យម្ចាស់ផ្ទះរុះរើសំយាបផ្ទះចេញដើម្បីកុំឱ្យក្រុមអាជីវករលក់ដូរបាននៅទីនោះបន្តទៅទៀត ។

ពួកក្រុមអាជីវករ ដែលអាជ្ញាធររាជធានីបង្ខំឱ្យរុះរើចេញនោះបានធ្វើការអង្វរ និងស្នើដល់លោកនាយករដ្ឋមន្ត្រីឱ្យជួយគិតគូរពីជីវភាព និងការរស់នៅរបស់ប្រជាពលរដ្ឋផង ។

យើងមិនអាចសុំការបំភ្លឺពីលោក **ម៉ប់ សារិន** និងលោក **ម៉ាន់ ឈឿន** អភិបាលរងរាជធានីភ្នំពេញបានទេ ដោយលោកប្រាប់ថាជាប់រវល់ ។

## អាជ្ញាធរស្រុកកំពង់លែងរងការចោទ ប្រកាន់ថាលួចលក់បឹងធម្មជាតិ

អាជ្ញាធរឃុំនៅក្នុងស្រុកកំពង់លែង ខេត្តកំពង់ឆ្នាំងរងការចោទប្រកាន់ថា បានលក់បឹងធម្មជាតិដែលធ្វើឱ្យប៉ះពាល់ដល់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋនៅស្រុកកំពង់លែង ។

សកម្មជនគណបក្សសិទ្ធិមនុស្សនៅស្រុកកំពង់លែង ថ្លែងថានៅស្រុកកំពង់លែងនេះ មានឃុំខ្លះត្រូវបានអាជ្ញាធរឃុំភូមិលួចសមគំនិតគ្នាលួចបឹងបួរលក់ទៅឱ្យឈ្មួញ តួយ៉ាងឃុំច្រណូក ក្នុងស្រុកកំពង់លែង ត្រូវបានមេឃុំលក់បឹងចំនួន១៨៣បឹង ។ ការលក់បឹងនេះកើតមាន២អាណត្តិមកហើយ។អាជ្ញាធរនេះក៏រងការចោទប្រកាន់ទៀតថា បានលក់ដីរាប់ពាន់ហិកតាទៀតផង ។ សកម្មជនរូបនោះថ្លែងទៀតថា ការលក់បឹងបួរធម្មជាតិនេះធ្វើឱ្យប៉ះពាល់ដល់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ ហើយនៅពេលដែលអ្នកភូមិយកក្របីឱ្យទៅដេកត្រាំទឹកបឹង ឬនេសាទត្រីលក្ខណៈគ្រួសារ ត្រូវបានម្ចាស់បឹងគេហាមឃាត់ ។

ប្រជាពលរដ្ឋម្នាក់នៅឃុំពោធិ៍ ក្នុងស្រុកកំពង់លែងបានឱ្យដឹងថា នៅក្នុងឃុំពោធិ៍ក៏មានការលក់បឹងបួ ស្ទើរតែអស់ទៅហើយពោលគឺនៅសេសសល់តែបឹងកំប៉ិកកំប៉ុកប៉ុណ្ណោះ ។ ទាក់ទងនឹងការលក់បឹងនេះ ប្រជាពលរដ្ឋបានតវ៉ាច្រើនលើកច្រើនសារ ប៉ុន្តែមិនដែលឈ្នះអាជ្ញាធរទាំងនោះទេ ។ លោកបានបន្តទៀតថា អាជ្ញាធរលក់បឹងធម្មជាតិទាំងនោះ ប្រៀបបាននឹងការកាត់ផ្តាច់អាជីពរបស់ប្រជាពលរដ្ឋ តួយ៉ាងការនេសាទ និងប្រើប្រាស់ទឹក ។ ជាមួយនឹងការលក់បឹងបួរ ក្នុងស្រុកកំពង់លែងលោក **ម៉ាន់ ណាន់លី** អភិបាលស្រុកកំពង់លែងមានប្រសាសន៍ថា បឹងទាំងអស់នៅក្នុងស្រុកកំពង់លែងគឺប្រជាពលរដ្ឋកំពុងតែធ្វើស្រែនៅជុំវិញបឹងនោះជារៀងរាល់ថ្ងៃ ។ លោកថា ករណីបឹងបួរនេះលោក និងមន្ត្រីជលផលចុះតាមមូលដ្ឋាននឹងប្រកាសជាទូទៅថា មិនមានអាជ្ញាធរ និងមានសមត្ថកិច្ចណាមានសិទ្ធិអំណាចក្នុងការលក់បឹងបួរនោះទេ ប៉ុន្តែបើបឹងទាំងនោះប្រជាពលរដ្ឋយកទឹកធ្វើស្រែតាំងពីសម័យសង្គ្រាមដូចជាកម្មសិទ្ធិរបស់ពួកគាត់ទៅហើយ តែបឹងបួរនេះមិនបានស្ថិតនៅក្នុងដៃបុគ្គលណាមួយនោះទេ ។

លោក **ប៉ែន សុវណ្ណ** ប្រធានគណៈកម្មាធិការវិន័យរបស់គណបក្សសិទ្ធិមនុស្សមានប្រសាសន៍ថា លោកបានចុះជួបប្រជាពលរដ្ឋនៅតាមមូលដ្ឋាន ហើយប្រជាពលរដ្ឋនៅគ្រប់ឃុំ ក្នុងស្រុកកំពង់លែងជម្រាបលោកថា បឹងជិត១000ត្រូវបានអាជ្ញាធរភូមិឃុំលក់អស់ហើយ ។ ការលក់បឹងព្រៃកនេះអាស្រ័យដោយមានការសម្រេចចិត្តពីថ្នាក់លើ បើកឱ្យមានអាណាធិបតេយ្យបំពានទៅលើសិទ្ធិអំណាចប្រជាពលរដ្ឋក្រីក្រ រំលោភលើធម្មជាតិដែលប្រជាពលរដ្ឋធ្លាប់ពឹងអាស្រ័យក្នុងជីវភាពរស់នៅ ។ លោកបន្ថែមថាលោកមានក្តីកង្វល់ណាស់ ដោយឃើញប្រជាពលរដ្ឋក្រីក្ររស់នៅពឹងអាស្រ័យលើបឹងនេះដើម្បីប្រកបរបរនេសាទ និងប្រកបរបរធ្វើស្រែប្រាំង ។ លោកសង្កត់ធ្ងន់ថា គណបក្សកាន់អំណាចមិនខ្វល់ខ្វាយចំពោះការការពារសម្បត្តិធម្មជាតិដែលប្រជាពលរដ្ឋធ្លាប់តែពឹងផ្អែកក្នុងជីវភាពរស់នៅ ។

លោក **សម ច័ន្ទគា** អ្នកសំរបសំរួលនៃសមាគម៏អាដហុកដែលមានមូលដ្ឋាននៅខេត្តកំពង់ឆ្នាំង បានបញ្ជាក់ថានៅឆ្នាំ២00៩នេះលោកមិនបានទទួលពតិមាន ឬពាក្យបណ្តឹងពីប្រជាពលរដ្ឋពាក់ព័ន្ធនឹងអាជ្ញាធរលក់បឹងបួរនោះទេ ប៉ុន្តែកាលពីឆ្នាំកន្លងទៅសមាគមអាដហុកបានទទួលពាក្យបណ្តឹងពីប្រជាពលរដ្ឋ និងតំណាងសហាគមន៏ដោយអាជ្ញាធរបានលក់បឹង ហើយយកលុយមកអភិវឌ្ឍន៏ ប៉ុន្តែមិនឃើញមានការអភិវឌ្ឍន៏អ្វីឱ្យច្បាស់លាស់នោះទេ ។

បច្ចុប្បន្ននេះគេសង្កេតឃើញថា ការលក់បឹងបួរព្រៃកព្រៃឈើនិយាយរួមគឺធនធានធម្មជាតិក្នុងស្រុកនៅតែកើតមាន ចំណែកគណបក្សកាន់អំណាចហាក់មិនមានវិធានការទប់ស្កាត់ នូវរាល់បទល្មើសទាំងនោះនៅឡើយទេ ។ នេះបង្ហាញឱ្យឃើញកាន់តែច្បាស់ថា អនាគតដ៏ខ្លីខាងមុខនេះ ធនធានធម្មជាតិនៅស្រុកខ្មែរនឹងវិនាសហិនហោច ។

## កម្មវិធីវគ្គបណ្តុះបណ្តាលសំរាប់យុវជន
## គណបក្សសិទ្ធិមនុស្ស
## មុខវិជ្ជាសិក្សា
## ជំនាញនៃការទំនាក់ទំនង

Communication Skills

**កម្មវិធីរួមមាន** - យុទ្ធសាស្រ្តនៃការទំនាក់ទំនង
Communication Strategy
- ពិធីការ
Protocol

កម្មវិធីនេះសិក្សានៅរៀងរាល់ថ្ងៃអង្គារ៏ រយៈពេលពីរសប្តាហ៏ សិក្សា៥ម៉ោងកន្លះ/ថ្ងៃ ។ ពេលបញ្ចប់វគ្គមានចេញលិខិតបញ្ជាក់ការសិក្សាជូនដោយឥតគិតថ្លៃជូនដល់សិក្ខាកាមផងដែរ ។ កម្មវិធីនេះមានបន្ថែមទៅលើកម្មវិធីសិក្សាជារៀងរាល់ថ្ងៃសុក្រ ។

| គ្រប់គ្រងការផ្សព្វផ្សាយ | | |
|---|---|---|
| **លោក** | **ម៉ី សាន** | ទូរស័ព្ទលេខ: 0១១ ៩0៤ 0៣១ |
| **កញ្ញា** | **គង់ វណ្ណា** | ទូរស័ព្ទលេខ: 0១២ ៨៦៥ ២៥៥ |
| ផ្ទះលេខ៧២-៧៤,ផ្លូវលេខ៥៩៨, សង្កាត់បឹងកក់២,ខណ្ឌទួលគោក,ក្រុងភ្នំពេញ | | |

**ធនធានធម្មជាតិនៅកម្ពុជាកំពុងរងការបំផ្លាញ !**